# ការស្វែងយល់ អំពី
# ការរៀបចំទទួលស្គាល់ទៅវិញទៅមកលើ

# វិជ្ជាជីវៈឯកទេសផ្នែកសេវាកម្មចំនួន ៨

## ក្រោមក្របខ័ណ្ឌចល័តកម្មសេរីកម្លាំងពលកម្មជំនាញ
## នៃ សហគមន៍សេដ្ឋកិច្ចអាស៊ាន



ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ភ្នំពេញ ២០១៧

# Understanding about
# Mutual Recognition Arrangement on

# 8 Professional Services

## Under Framework of
## Free Skilled Labour Mobility of the
## ASEAN Economic Community



National Employment Agency
Phnom Penh, 2017

# សហគមន៍សេដ្ឋកិច្ចអាស៊ាន

## ១. សាវតាសង្ខេប

ក្នុងខែធ្នូ ឆ្នាំ១៩៩៧ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់បានសម្រេចចិត្តក្នុងប្រែក្លាយអាស៊ានទៅជាតំបន់មួយដែលមានស្ថិរភាព វឌ្ឍនភាព និងភាពប្រកួតប្រជែងខ្ពស់ តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ ព្រមទាំងកាត់បន្ថយភាពក្រីក្រ និងគម្លាតផ្នែកសង្គម-សេដ្ឋកិច្ច។

បន្ទាប់ពីមានកិច្ចជំនួបកំពូលកម្រិតថ្នាក់ដឹកនាំ និងផ្នែកបច្ចេកទេសជាច្រើនលើក នៅក្នុងជំនួបកំពូលអាស៊ានលើកទី១២ ក្នុងខែមករា ឆ្នាំ២០០៧ ថ្នាក់ដឹកនាំនៃប្រទេសសមាជិកទាំងអស់បានបង្ហាញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការជំរុញបង្កើតនូវ **«សហគមន៍អាស៊ាន»** ឲ្យបានក្នុងឆ្នាំ២០១៥ ស្របតាមចក្ខុវិស័យអាស៊ាន ២០២០។ ជាពិសេសថ្នាក់ដឹកនាំទាំងអស់បានឯកភាពគ្នាលើការជំរុញបង្កើតឲ្យកាន់តែឆាប់រហ័សនូវ **«សហគមន៍សេដ្ឋកិច្ចអាស៊ាន»** ក្នុងឆ្នាំ២០១៥ ដើម្បីប្រែក្លាយអាស៊ានទៅជាតំបន់ដែលមានលំហូរដោយសេរីនូវ ផលិតផលទំនិញ, សេវាកម្ម, ការវិនិយោគ, កម្លាំងពលកម្មជំនាញ និងមូលធន។

## ២. សហគមន៍សេដ្ឋកិច្ចអាស៊ានជាអ្វី?

សហគមន៍សេដ្ឋកិច្ចអាស៊ានគឺជាការធ្វើឲ្យសម្រេចនូវគោលបំណងចុងក្រោយនៃសមាហរណកម្មសេដ្ឋកិច្ច ដូចដែលបានកំណត់នៅក្នុងចក្ខុវិស័យអាស៊ាន២០២០ ដោយផ្អែកលើការរួមបញ្ចូលគ្នានូវផលប្រយោជន៍នៃប្រទេសសមាជិកអាស៊ានទាំងអស់ដើម្បីធ្វើឲ្យកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកាន់តែស៊ីជម្រៅ និងទូលំទូលាយស្របតាមគំនិតផ្តួចផ្តើមមានស្រាប់ និងថ្មីៗក្នុងពេលវេលាជាក់លាក់។

សហគមន៍សេដ្ឋកិច្ចអាស៊ានរំពឹងថានឹងសម្រេចឲ្យបាននូវលក្ខខណ្ឌគន្លឹះខាងក្រោម៖ (ក). មូលដ្ឋាននៃទីផ្សារនិងផលិតផលរួម, (ខ). តំបន់ដែលមានការប្រកួតប្រជែងខ្លាំងក្លាផ្នែកសេដ្ឋកិច្ច, (គ). តំបន់ដែលមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌, (គ). តំបន់ដែលមានការធ្វើសមាហរណកម្មពេញលេញចូលទៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសាកលលោក។

---

*ប្រភព: ASEAN Economic Community Blueprint, ASEAN Secretariat, 2008.*

◉ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ជាភ្នាក់ងាររបស់រាជរដ្ឋាភិបាលមានតួនាទីភារកិច្ចក្នុងការផ្តល់ «**សេវាការងារ និងព័ត៌មានទីផ្សារការងារ**» នៅកម្ពុជា ដល់និយោជក អ្នកស្វែងរកការងារ អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងសាធារណជន។ ទីភ្នាក់ងារត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិបណ្តុះបណ្តាល។ ដើម្បីផ្តល់សេវាកាន់តែងាយស្រួល និងឆាប់រហ័ស ទីភ្នាក់ងារនេះបានបង្កើតនូវមធ្យោបាយផ្តល់សេវាដូចខាងក្រោម៖

- មជ្ឈមណ្ឌលការងារ (បច្ចុប្បន្នស្ថិតនៅ រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កំពត ស្វាយរៀង តាកែវ កំពង់ចាម កំពង់ធំ ព្រៃវែង បន្ទាយមានជ័យ និងខេត្តព្រះសីហនុ)
- គេហទំព័រ www.nea.gov.kh
- ហ្វេសប៊ុក www.facebook.com/neakhmer
- កម្មវិធីស្វែងរកការងារក្នុងទូរស័ព្ទដៃប្រព័ន្ធAndroid «NEA Job Search»

◉ អាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)


- ទូរស័ព្ទលេខ ០២៣ ៨៨៤ ៦៩២
០៨៨ ៦៧៨ ៥៦៧៨
- អ៊ីម៉េល info@nea.gov.kh





©រក្សាសិទ្ធិដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឆ្នាំ២០១៧



បោះពុម្ពក្រោមគម្រោង ILO-SIDA ស្តីពី «ការពង្រឹងមគ្គុទេសក៍អាជីព, ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញទន់ ដល់សិស្សមធ្យមសិក្សាបឋម/ទុតិយភូមិ និងវិទ្យាស្ថានTVET»
រៀបរៀង និងរចនាៈ **ហៃ ហ៊ុនឡេង**